**សុន្ទរកថាស្វាគមន៍**
**របស់ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ក្នុងពិធីសម្ពោធពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ**
**ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ**

**ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៥:០០នាទីរសៀល**
**ទីតាំងបរិវេណមជ្ឈមណ្ឌលវិមានសុភមង្គល**
**សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ**

សូមគោរព៖

- **ឯកឧត្តម ម៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរព!
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយស ជាទីមេត្រី!

តាងនាម ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តម **ម៉ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទីស្តីការគណៈរដ្ឋមន្ត្រី** ដែលបានចំណាយពេលវេលាដ៏មមាញឹក អញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធ **"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"** ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម ពីថ្ងៃទី២៦-២៩ ខែតុលា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលវិមានសុភមង្គល នាពេលនេះ។ ខ្ញុំបាទក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅផងដែរ ចំពោះវត្តមានឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួម និងគាំទ្រ **យុទ្ធនាការទិញផលិតផលខ្មែរ** ញ៉ាំងឱ្យព្រឹត្តិការណ៍ពាណិជ្ជកម្មយើងកាន់តែមានភាពអធិកអធមថែមទៀត។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **គណៈអធិបតី** ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ ឱ្យបានជ្រាបថា ស្ថិតក្នុងដំណាក់កាលដែលមានការប្រកួតប្រជែងយ៉ាងស្រួចស្រាល់ ក្នុងក្របខ័ណ្ឌទូទាំងពិភពលោក និងដោយមានបំណងជួយជាងចក្រ សហគ្រាស សិប្បកម្ម និងផលិតកម្មទាំងឡាយនៅកម្ពុជា ក្រសួងពាណិជ្ជកម្ម បានផ្តើមគំនិតរៀបចំ **"យុទ្ធនាការទិញផលិត**



Scanned by CamScanner

ផលខ្មែរ" ដើម្បីទាក់ទាញប្រជាពលរដ្ឋ ឱ្យងាកមកប្រើប្រាស់ផលិតផលក្នុងស្រុកឱ្យបានទូលំទូលាយ សំដៅកាត់បន្ថយការនាំចូលទំនិញពីបរទេស។ ដើម្បីសម្រេចបានគោលបំណងនេះ យើងបានកំណត់គោលដៅជាយុទ្ធសាស្ត្រថា **ផលិតផលខ្មែរ ត្រូវមានគុណភាព មានសុវត្ថិភាព មានសោភ័ណភាព និងមានតម្លៃសមរម្យ។**

សកម្មភាពចម្បងៗនៃ**យុទ្ធនាការទិញផលិតផលខ្មែរ** រួមមាន៖

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងកិច្ចពិភាក្សា ដើម្បីជម្រាបដល់អ្នកផលិតឱ្យយល់ពីគោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការជួយពង្រឹងផលិតកម្មក្នុងស្រុក ព្រមទាំងណែនាំឱ្យ អ្នកផលិត យកចិត្តទុកដាក់ផលិតនូវទំនិញដែលមានគុណភាព, ធានាបាននូវសុវត្ថិភាពប្រើប្រាស់, ការវេចខ្ចប់មានសោភ័ណភាពទាក់ទាញ និងមានតម្លៃសមរម្យ,
- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងយុទ្ធនាការនេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា ទូរទស្សន៍ វិទ្យុ កាសែត បណ្តាញសង្គម ដើម្បីឱ្យប្រជាពលរដ្ឋមានការចាប់អារម្មណ៍ ទទួលស្គាល់ និងងាកមកប្រើប្រាស់ផលិតផលក្នុងស្រុក,
- រៀបចំកម្មវិធីពិភាក្សា និងជំនួបរវាងអ្នកផលិត និងអ្នកប្រើប្រាស់, និង
- ជ្រើសរើសផលិតផលខ្មែរ ដែលមានសក្តានុពលមកតាំងបង្ហាញ និងដាក់លក់ជូនសាធារណជន ព្រមទាំងមានការប្រគំតន្ត្រីកំដរនាពេលរាត្រីផង។

**យុទ្ធនាការទិញផលិតផលខ្មែរ** គឺជាសំឡេងជួងពញាក់ស្មារតីអ្នកប្រើប្រាស់ទាំងឡាយឱ្យងាកមកប្រើប្រាស់ទំនិញក្នុងស្រុក, កាត់បន្ថយការហូរចូលទំនិញពីបរទេស, ជំរុញការនាំចេញផលិតផលខ្មែរទៅក្រៅប្រទេស, រួមចំណែកជួយពង្រឹងសមត្ថភាពផលិត និងបង្កើនការងារក្នុងស្រុក។ យុទ្ធនាការនេះ ក៏នឹងផ្តល់ការយល់ដឹងខ្ពស់ដល់អ្នកផលិតក្នុងស្រុក ធ្វើយ៉ាងណាផលិតនូវទំនិញដែលមានគុណភាពខ្ពស់, មានអនាម័យធានាសុវត្ថិភាពប្រើប្រាស់, មានសោភ័ណភាពទាក់ទាញ និងមានតម្លៃសមរម្យ អាចប្រកួតប្រជែងជាមួយទំនិញនាំចូល។ ការសម្រេចបានជោគជ័យក្នុងការធ្វើយុទ្ធនាការទិញផលិតផលខ្មែរ នឹងជួយកម្ពុជាឱ្យ៖

- បង្កបាននូវបរិយាកាសអាជីវកម្ម ពាណិជ្ជកម្មក្នុងស្រុកកាន់តែល្អប្រសើរ,
- បង្កើនលទ្ធភាពផលិតកម្មក្នុងស្រុក និងបង្កើនតម្លៃបន្ថែមលើផលិតផលក្នុងស្រុកបានជាអតិបរិមា
- ផលិតនូវទំនិញថ្មីៗ បម្រើសេចក្តីត្រូវការក្នុងស្រុក កាត់បន្ថយការនាំចូល និងជំរុញការនាំចេញ
- ធ្វើពិពិធកម្មមុខទំនិញថ្មីៗ ដែលមានលទ្ធភាពប្រកួតប្រជែងទាំងលើទីផ្សារក្នុងស្រុក ទីផ្សារក្នុងតំបន់ និងទីផ្សារពិភពលោក,
- បង្កើតបាននូវការងារថ្មីៗថែមទៀត ជួយបង្កើនប្រាក់ចំណូល ជួយទប់ស្កាត់ការធ្វើចំណាកស្រុក និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។



Scanned by CamScanner

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

កន្លងទៅ ក្រសួងពាណិជ្ជកម្ម បានរៀបចំដោយជោគជ័យនូវ **យុទ្ធនាការទិញផលិតផលខ្មែរ** ជើងកាលទី១ ឆ្នាំ២០១៦ នៅខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ នៅឆ្នាំ២០១៧ ក្រសួងពាណិជ្ជកម្ម បាន និងកំពុងរៀបចំ **យុទ្ធនាការទិញផលិតផលខ្មែរ** ជើងកាលទី២ តាមកាលបរិច្ឆេទដូចខាងក្រោម៖

១-ខេត្តបាត់ដំបង ៖ -ពិព័រណ៌ពាណិជ្ជកម្ម កាលពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១៧
-សិក្ខាសាលា កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

២-ខេត្តស្វាយរៀង ៖ -ពិព័រណ៌ពាណិជ្ជកម្ម កាលពីថ្ងៃទី២២-២៥ ខែមិថុនា ឆ្នាំ២០១៧
-សិក្ខាសាលា កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧

៣-រាជធានីភ្នំពេញ ៖ -ពិព័រណ៌ពាណិជ្ជកម្ម កំពុងរៀបចំពីថ្ងៃទី២៦-២៩ ខែតុលា ឆ្នាំ២០១៧

៤-ខេត្តកែប ៖ -ពិព័រណ៌ពាណិជ្ជកម្ម នឹងរៀបចំពីថ្ងៃទី២១-២៤ ខែធ្នូ ឆ្នាំ២០១៧

**ពិព័រណ៌ពាណិជ្ជកម្មផលិតផលខ្មែរ** ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ នៅរាជធានីភ្នំពេញនាពេលនេះ ទទួលបានការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីផលិតករ អាជីវករ សមាគម អង្គការនានា ដោយមានក្រុមហ៊ុនសរុបចំនួន ១៩៤ក្រុមហ៊ុន បានដាក់ពាក្យស្នើសុំចូលរួមដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន ក្នុងស្តង់សរុបចំនួន ២០០ស្តង់។

ផលិតផល និងសេវាជាច្រើនប្រភេទ ត្រូវបានដាក់តាំងបង្ហាញក្នុងព្រឹត្តិការណ៍ពាណិជ្ជកម្មនេះ រួមមាន ផលិតផលកសិ-ពាណិជ្ជកម្ម ផលិតផលសិប្បកម្ម វត្ថុអនុស្សាវរីយ៍, ផលិតផលម្ហូបអាហារ និងភេសជ្ជៈ, ផលិតផលសុខភាព និងសម្រស់, សេវាទេសចរណ៍ និងអប់រំ, ផលិតផលសំណង់ និងផលិតផលប្រើប្រាស់ទូទៅផ្សេងៗ ជាច្រើនទៀត។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្រៅពីសកម្មភាពដាក់តាំងបង្ហាញផលិតផលខ្មែរ ការរៀបចំសិក្ខាសាលា និងការប្រគំតន្ត្រី ក្នុងយុទ្ធនាការទិញផលិតផលខ្មែរ ក្រសួងពាណិជ្ជកម្ម បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងទេសចរណ៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំវេទិកាជំនួបពិគ្រោះយោបល់ចំនួន ២លើករួចមកហើយ **រវាងអ្នកផលិត អ្នកផ្គត់ផ្គង់ផលិតផលខ្មែរ** និង**អ្នកបញ្ជាទិញ អ្នកប្រើប្រាស់ ផលិតផលខ្មែរ** ដូចជា ផ្សារទំនើប សណ្ឋាគារ និងភោជនីយដ្ឋាន។ នៅក្នុងជំនួបដ៏កម្រនោះ **ភាគីអ្នកផលិត អ្នកផ្គត់ផ្គង់ផលិតផលខ្មែរ** និង **ភាគីអ្នកបញ្ជាទិញ អ្នកប្រើប្រាស់ផលិតផលខ្មែរ** មានឱកាសបានលើកឡើងពីចំណុចខ្លាំង ចំណុចខ្សោយ ភាពងាយស្រួល ការលំបាក និងសំណូមពររបស់ខ្លួនជូនរដ្ឋមន្ត្រីទាំង៤ក្រសួង ឆ្លើយតប និងដោះស្រាយជូនតាមសមត្ថកិច្ចរៀងៗខ្លួន។ ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងទេសចរណ៍,



Scanned by CamScanner

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏នឹងបន្តរៀបចំវេទិកាជំនួបបែបនេះជាបន្តទៀត នាពេលខាងមុខ។

ជាទីបញ្ចប់ ជួសមុខឱ្យក្រសួងពាណិជ្ជកម្ម ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានអញ្ជើញធ្វើជាអធិបតីក្នុងពិធីសម្ពោធ **"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"**, វគ្គកាលទី២នេះ សូមថ្លែងអំណរគុណចំពោះកិច្ចសហការយ៉ាងល្អរបស់ភាគីពាក់ព័ន្ធទាំងអស់ ពិសេស អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមក្នុងពិធីសម្ពោធពិព័រណ៍នៅវេលានេះ។

ខ្ញុំបាទសូមគោរពជូនពរចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**



Scanned by CamScanner